# សន្និសីទជាតិ
# ស្ដីពី
# កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ៖ " មេរៀនបទពិសោធន៍ បញ្ហាប្រឈម និងចក្ខុវិស័យទៅអនាគត "

ថ្ងៃ៧-៨កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី២១-២២ ខែកុម្ភៈ ឆ្នាំ២០១៨
រាជធានីភ្នំពេញ មជ្ឈមណ្ឌលសន្និបាតកោះពេជ្រ

## របាយការណ៍សង្ខេបស្ដីពីលទ្ធផលនៃសន្និសីទជាតិ

ដោយ **សម្ដេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប

- សូមគោរព **សម្ដេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់
- ឯកឧត្ដម លោកជំទាវជាសមាជិក សមាជិការាជរដ្ឋាភិបាល
- ឯកឧត្ដមឯកអគ្គរាជទូត និងអគ្គរដ្ឋទូត
- ឯកឧត្ដម លោកជំទាវ លោក លោកស្រីតំណាងក្រសួង ស្ថាប័ន និងថ្នាក់ដឹកនាំរដ្ឋបាលថ្នាក់ក្រោមជាតិ
- ឯកឧត្ដម លោកជំទាវ លោក លោកស្រីតំណាងដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល
- អង្គសន្និសីទជាតិទាំងមូលជាទីមេត្រី!

ក្នុងនាមគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងតាំងនាមឱ្យសមាជិក សមាជិកានៃអង្គសន្និសីទជាតិទាំងមូល ខ្ញុំសូមសម្ដែងនូវគារវកិច្ចគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុតចំពោះវត្តមានដ៏ឧត្ដុងឧត្ដមរបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា ដែល **សម្ដេច** បានឆ្លៀតឱកាសដ៏មមាញឹកក្នុងបេសកកម្មដ៏ថ្លៃថ្លាបម្រើជាតិ និងប្រជាជន អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីបិទសន្និសីទជាតិនាពេលនេះ។ ក្នុងឱកាសដ៏មហោឡារិកអធិកអធមនេះ ខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់ សូមគោរពអនុញ្ញាតធ្វើសេចក្ដីរាយការណ៍ដោយសង្ខេបជូន **សម្ដេចតេជោ នាយករដ្ឋមន្ត្រី** អំពីលទ្ធផលនៃសន្និសីទជាតិស្ដីពីវិមជ្ឈការ និងវិសហមជ្ឈការដែលបានប្រព្រឹត្តទៅចាប់ពីព្រឹកម្សិលមិញរហូតមកដល់ពេលនេះ ដូចតទៅ ៖

### ១. អំពីអ្នកចូលរួម

សន្និសីទជាតិនេះមានការចូលរួមពីសមាជិក សមាជិកាប្រមាណជាង២.៧០០នាក់ ដែលមានសមាសភាពជាសមាជិកនៃ គ.ជ.អ.ប. រដ្ឋមន្ត្រី ប្រធានស្ថាប័នពាក់ព័ន្ធ ប្រធានក្រុមការងារ

បច្ចេកទេសវិមជ្ឈការនិងវិសហមជ្ឈការ និងអគ្គនាយកពាក់ព័ន្ធនានានៃក្រសួង ស្ថាប័ន ប្រធានក្រុមប្រឹក្សា អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ទូទាំងប្រទេស ប្រធានមន្ទីរ អង្គភាពជំនាញពាក់ព័ន្ធមួយចំនួននៅរាជធានី ខេត្ត តំណាងដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលពាក់ព័ន្ធនានា។

## ២. អំពីកិច្ចដំណើរការ

សន្និសីទជាតិនេះបានរៀបចំពិធីបើកកាលព្រឹកម្សិលមិញ ក្រោមការដឹកនាំដោយរូបខ្ញុំផ្ទាល់។ បន្ទាប់ពីពិធីបើក អង្គសន្និសីទជាតិបានស្តាប់របាយការណ៍ និងបទអន្តរាគមន៍នានាដែលក្នុងនោះរួមមាន ៖

- របាយការណ៍អំពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងកិច្ចការជាអាទិភាពនានាដែលត្រូវបន្តអនុវត្តក្នុងរយៈពេល៣ឆ្នាំចុងក្រោយនៃកម្មវិធីជាតិចាប់ពីឆ្នាំ២០១៨នេះទៅដល់ឆ្នាំ២០២០
- បទបង្ហាញរបស់ជំនាញការអន្តរជាតិ ដើម្បីចែករំលែកអំពីមេរៀនបទពិសោធន៍ពាក់ព័ន្ធនឹងការធ្វើវិមជ្ឈការ និងវិសហមជ្ឈការនៅក្នុងបណ្តាប្រទេសនានាក្នុងតំបន់អាស៊ីអាគ្នេយ៍
- បទអន្តរាគមន៍របស់តំណាងរដ្ឋបាលរាជធានី ខេត្ត តំណាងរដ្ឋបាលក្រុង ស្រុក តំណាងរដ្ឋបាលឃុំ សង្កាត់ និងតំណាងសមាគមក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ អំពីស្ថានភាព និងបញ្ហាប្រឈមដែលបានជួបប្រទះជាក់ស្តែងក្នុងការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់
- បទអន្តរាគមន៍របស់តំណាងក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមុខងារសាធារណៈ ក្រសួងកិច្ចការនារី និងតំណាងអង្គការសង្គមស៊ីវិលអំពីការបន្តពង្រឹងរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការបន្តជំរុញការធ្វើវិមជ្ឈការហិរញ្ញវត្ថុដើម្បីធានាដល់ការបង្កើនធនធានហិរញ្ញវត្ថុ និងសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការពង្រឹងប្រព័ន្ធគ្រប់គ្រងបុគ្គលិក និងការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម និងការបន្តពង្រឹងភាពជាដៃគូរបស់អង្គការសង្គមស៊ីវិលក្នុងការចូលរួម និងគាំទ្រដល់កិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

បន្ទាប់ពីបានស្តាប់នូវបទបង្ហាញ និងបទអន្តរាគមន៍នានា អង្គសន្និសីទជាតិក៏បានរៀបចំវេទិកាសំណួរ-ចម្លើយជាមួយវាគ្មិនសំខាន់ៗដែលជាតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធនានាក្រោមប្រធានបទ "**ការលើកកម្ពស់តួនាទីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន និងការផ្តល់សេវាសាធារណៈក្នុងក្របខ័ណ្ឌនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ**"។

## ៣. អំពីលទ្ធផល

ជារួម ផ្អែកតាមរបាយការណ៍ បទអន្តរាគមន៍ និងការជជែកពិភាក្សា អង្គសន្និសីទទាំងមូលបានឯកភាព និងវាយតម្លៃខ្ពស់ចំពោះការប្តេជ្ញាចិត្តដ៏មុតមាំរបស់រាជរដ្ឋាភិបាល ការចូលរួម និងការគាំទ្រពីក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធនានាក្នុងកិច្ចដំណើរការកំណែទម្រង់ដ៏មានសារៈសំខាន់នេះឱ្យសម្រេចបាននូវសមិទ្ធផលសំខាន់ៗជាច្រើន ក្នុងការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធ ប្រព័ន្ធ និងនីតិវិធីអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ អភិបាលកិច្ចល្អលើមូលដ្ឋាននៃការចូលរួម តម្លាភាព និងគណនេយ្យភាពក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ដើម្បីបម្រើសេចក្តីត្រូវការបាច់របស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាននីមួយៗ។

អាស្រ័យដោយការប្តេជ្ញាចិត្តនេះ ចាប់ពីឆ្នាំ២០០២ រហូតដល់ឆ្នាំ២០១៧ រាជរដ្ឋាភិបាលបានផ្ទេរថវិការដ្ឋប្រមាណជាង**២ពាន់លានដុល្លារអាមេរិក** ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងបានកៀរគរថវិកាពីដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធនានាប្រមាណ**៥៧០លានដុល្លារអាមេរិក** ក្នុងការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ ផ្អែកលើធនធានដែលទទួលបានទាំងនេះ រដ្ឋបាលថ្នាក់ក្រោមជាតិបានរៀបចំ និងអនុវត្តគម្រោងអភិវឌ្ឍមូលដ្ឋានទាំងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងអរូបវ័ន្តប្រមាណ**១.៨០០គម្រោង**ក្នុងមួយឆ្នាំៗ ដើម្បីផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន។

ផ្អែកលើសមិទ្ធផលទាំងនេះបង្ហាញឱ្យឃើញថា កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការលើកកម្ពស់អភិបាលកិច្ចល្អ ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ ការខិតខំដោះស្រាយនូវបញ្ហាប្រឈមនានាជាច្រើននៅមូលដ្ឋាន ដើម្បីចូលរួមចំណែកលើកស្ទួយជីវភាពរស់នៅ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព និងសមធម៌។

ទោះយ៉ាងនេះក្តី ក៏ការអនុវត្តកំណែទម្រង់នេះនៅជួបប្រទះបញ្ហាប្រឈមជាគន្លឹះមួយចំនួនដែលត្រូវបន្តដោះស្រាយ ជាអាទិ៍៖

- រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ទោះបីត្រូវបានរៀបចំកែសម្រួលជាបន្តបន្ទាប់ ក៏ប៉ុន្តែនៅពុំទាន់ឆ្លើយតបទៅនឹងការវិវឌ្ឍផ្នែកសេដ្ឋកិច្ចសង្គមកិច្ច ដែលមានការរីកចម្រើនយ៉ាងឆាប់រហ័សទាំងនៅតំបន់ទីក្រុង ទីប្រជុំជន និងជនបទ។
- ការចូលរួមពីក្រសួង ស្ថាប័នក្នុងដំណើរការនៃការផ្ទេរមុខងារ និងធនធានក្នុងដំណាក់កាលដ៏ស៊ីជម្រៅនេះនៅមិនទាន់ស្រុះស្រួល និងស្មើដៃគ្នានៅឡើយ។

- ទំហំមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ ទោះបីជាមានការកើនឡើងជារៀងរាល់ឆ្នាំ ក៏ប៉ុន្តែអាស្រ័យដោយការរីកចម្រើនយ៉ាងលឿនផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ច បានធ្វើឱ្យមានការកើនឡើងនូវតម្រូវការនានានៅតាមមូលដ្ឋានដែលបានដាក់សម្ពាធមកលើរដ្ឋបាលមូលដ្ឋានក្នុងការប្រើប្រាស់ធនធានទាំងនេះ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាជន។
- ក្រៅពីនេះ ក៏នៅមានបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងតួនាទី ការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការលើកកម្ពស់សមភាពយេនឌ័រ ការជួយគាំពារដល់ជនងាយរងគ្រោះ ចាស់ជរា ការឆ្លើយតបទៅនឹងតម្រូវការរបស់ស្ត្រី កុមារ យុវជន ជនជាតិដើមភាគតិច ព្រមទាំងការឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ និងគ្រោះធម្មជាតិ ដែលបញ្ហាប្រឈមទាំងនេះ តែងតែដាក់សម្ពាធមកលើរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការឆ្លើយតបជាបឋម និងភ្លាមៗនៅមូលដ្ឋាន។

បញ្ហាប្រឈមសំខាន់ៗដូចបានគោរពរាយការណ៍ជូនខាងលើនេះ អង្គសន្និសីទទាំងមូលបានឯកភាពស្រុះស្រួលគ្នា ប្តេជ្ញាចិត្តបន្តខិតខំដោះស្រាយតាមរយៈការអនុវត្តផែនការដំណាក់កាលចុងក្រោយនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដោយចាប់ផ្តើមពីការអនុវត្តផែនការសកម្មភាព និងថវិកាឆ្នាំ២០១៨នេះតទៅ។

ក្នុងឱកាសដ៏វិសេសវិសាលថ្លៃថ្លានេះ ក្នុងនាម គ.ជ.អ.ប និងអង្គសន្និសីទទាំងមូល យើងខ្ញុំសូមគោរពអញ្ជើញ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ថ្លែងសុន្ទរកថាបិទសន្និសីទជាតិ ព្រមទាំងផ្តល់អនុសាសន៍ដឹកនាំណែនាំសម្រាប់ជាពុទ្ធិ និងសម្រាប់ជាឋាមពលដល់យើងខ្ញុំទាំងអស់គ្នាបន្តជំរុញកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការឱ្យឈានឆ្ពោះទៅសម្រេចបានសមិទ្ធផលស្របតាមគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់ការផ្តល់សេវាសាធារណៈ ការអភិវឌ្ឍសេដ្ឋកិច្ច សង្គមប្រកបដោយចីរភាព និងបរិយាប័ន្ន សំដៅបម្រើផលប្រយោជន៍នៃប្រជាជនកម្ពុជាគ្រប់ៗរូប។

ចុងបញ្ចប់នេះ ក្នុងនាម គ.ជ.អ.ប និងអង្គសន្និសីទទាំងមូល និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមគោរពជូនពរបវរមហាប្រសើរជូន**សម្តេចតេជោនាយករដ្ឋមន្ត្រី** សូមមានសុខភាពល្អបរិបូរណ៍ និងសម្រេចបានជោគជ័យយ៉ាងត្រចះត្រចង់ដើម្បីបម្រើជាតិ និងប្រជាជនកម្ពុជា។

សូមគោរពអញ្ជើញ **សម្តេច** ។